រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ២៥៩ ប្រក.សហវ.ពដ**

**ស្តីពីការរៀបចំអោយមានផ្នែកកំណត់មូលដ្ឋាន**

**គិតពន្ធនិងផ្នែកប្រមូលពន្ធ នៅក្នុងសាខាពន្ធដារខេត្ត-ក្រុង**

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបទបញ្ញត្តទូទៅ នៃគណនេយ្យសាធារណៈ ពិសេសមាត្រា ៣,៤,៧ ដល់ ១៨ មាត្រា ២២ មាត្រា ២៦ ដល់៣៣ មាត្រា ៦៨ដល់ មាត្រា ៨០ មាត្រា ៩៤ ដល់១០០ មាត្រា ១០២ ដល់១០៦ និងមាត្រា ១១១

– យោងតាមការចាំបាច់ នៃការងាររបស់ផ្នែកពន្ធដារ

**សំរេច**

**ប្រការ ១ .–**

អនុវត្តតាមគោលការណ៍ នៃការបែងចែកអាណាប័ក និងគណនេយ្យករ ចាប់ពីពេលនេះតទៅ នៅក្នុងសាខាពន្ធដារគ្រប់ខេត្ត–ក្រុង ត្រូវបានបំបែកការងារកំណត់មូលដ្ឋានគិតពន្ធអាករ ចេញពីការងារប្រមូលពន្ធអាករ និងប្រាក់ពិន័យពីទោសទ័ណ្ឌសារពើពន្ធ ។

**ប្រការ ២ .–**

ប្រធានអង្គភាពពន្ធដារថ្នាក់ស្រុក–ខ័ណ្ឌ មានភារកិច្ចទទួលខុសត្រូវ :

–កំណត់មូលដ្ឋានគិតពន្ធអាករ គណនា និងត្រួតពិនិត្យពន្ធអាករ និងប្រាក់ពិន័យពីទោសទ័ណ្ឌដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

–បើកអោយមានសំណុំឯកសារមួយ សំរាប់អ្នកជាប់ពន្ធម្នាក់ៗ ដែលមានប្រាក់ចំណូលត្រូវជាប់ពន្ធអាករតាមរបបឆ្លើយប្រកាស ។

–បង្កើតបញ្ជីពន្ធប្រចាំខែ ឬ ប្រចាំត្រីមាស ចំពោះពន្ធអាករដែលមិនមែនជាកម្មវត្ថុនៃការឆ្លើយប្រកាសដែលត្រូវអមតាមដោយការបង់ប្រាក់ដោយម្ចាស់ការ ។

**ប្រការ ៣ .–**

ប្រគល់សិទ្ធិជូនប្រធានសាខាពន្ធដារខេត្ត–ក្រុង ជាអាណាប័កទទួលសិទ្ធិប្រទានក្នុងការអនុវត្តមតិបញ្ជីពន្ធ ។

បញ្ជីពន្ធត្រូវបញ្ជូនអោយគណនេយ្យករពន្ធដារ ដែលមានសមត្ថកិច្ចសំរាប់ធ្វើជាការទទួលបន្ទុកទារប្រមូល ។

ការទទួលបន្ទុកទារប្រមូល ត្រូវប្រព្រឹត្តទៅដោយការបង្កើតដីកាចំណូលឯ...ទុត ។

**ប្រការ ៤ .–**

នៅសាខាពន្ធដាខេត្ត–ក្រុងនីមួយៗ ត្រូវបានបង្កើតអោយមានប៉ុស្តិ៍គណនេយ្យនានាសំរាប់ប្រមូលប្រាក់ពន្ធអាករ និងប្រាក់ពិន័យពីទោសទ័ណ្ឌ ដែលទាក់ទងនឹងពន្ធអាករទាំងឡាយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សាខាពន្ធដារខេត្ត–ក្រុង ។

**ប្រការ ៥ .–**

ការដឹកនាំការងាររបស់ប៉ុស្តិ៍គណនេយ្យពន្ធដារនីមួយៗ ត្រូវបានប្រគល់ជូនតែគណនេយ្យករមួយរូបប៉ុណ្ណោះ ដែលជាអ្នកមានលក្ខណៈសម្បត្តិជាគណនេយ្យករសាធារណៈ ។

គណនេយ្យករពន្ធដារ ដែលបំពេញមុខងាររបស់ខ្លួននៅទីចាត់ការ នៃសាខាពន្ធដារខេត្ត–ក្រុង មានលក្ខណៈសម្បត្តិជាគណនេយ្យករដើមខ្សែ ។

គណនេយ្យករពន្ធដារ ដែលបំពេញមុខងាររបស់ខ្លួននៅអង្គភាពពន្ធថ្នាក់ស្រុក–ខ័ណ្ឌ មានលក្ខណៈសម្បត្តិជាគណនេយ្យកររង ។

**ប្រការ ៦ .–**

ការទទួលខុសត្រូវ និងការតព្វកិច្ចរបស់គណនេយ្យករពន្ធដារ គឺជាការទទួលខុសត្រូវ និងការតព្វកិច្ចរបស់គណនេយ្យករសាធារណៈ ដូចបានចង្អុលបញ្ជាក់ក្នុងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ ។

**ប្រការ ៧ .–**

គណនាគកររងត្រូវទទួលបន្ទុកធ្វើបេឡានិច្ច័យ និងធ្វើគណនេយ្យកម្មប្រាក់ពន្ធដែលបានគណនេយ្យនាដោយផ្នែកកំណត់មូលដ្ឋានគិតពន្ធ នៃអង្គភាពពន្ធដារថ្នាក់ស្រុក–ខ័ណ្ឌ ។

គណនេយ្យករដើមខ្សែត្រូវទទួលបន្ទុកធ្វើបេឡានិច្ច័យ និងធ្វើគណនេយ្យកម្មប្រាក់ពន្ធដែលបានគណនាដោយផ្នែកកំណត់ពន្ធនៃទីចាត់ការរបស់សាខាពន្ធដារខេត្ត–ក្រុង ។

គណនេយ្យករដើមខ្សែក៏មានសមត្ថកិច្ចផងដែរ ក្នុងការធ្វើកិច្ចការទារប្រមូលតាមរបៀបបង្ខំនូវប្រាក់ពន្ធអាករ ឬ ប្រាក់ពិន័យពីទោសទណ្ឌនានា ដែលត្រូវបានគណនាដោយផ្នែកកំណត់ពន្ធណាមួយ ដែលស្ថិតក្នុងដែនដីនៃដែនអំណាចរបស់សាខាពន្ធដារខេត្ត–ក្រុង ហើយដែលមិនបានបង់ក្នុងរយៈពេលដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

គណនេយ្យករដើមខ្សែ ប្រមូលផ្តុំប្រតិបត្តិការដែលបានធ្វើគណនេយ្យកម្មដោយគណនេយ្យកររង និង បង្កើតស្ថិតិ នៃការប្រមូលពន្ធដោយសាខាពន្ធដារខេត្ត–ក្រុង ។

គណនេយ្យកររង និង គណនេយ្យករដើមខ្សែ ត្រូវចាត់ចែងក្រោមការទទួលខុសត្រូវរបស់ខ្លួន នូវការផ្ទេរប្រាក់ដែលខ្លួនបានធ្វើបេឡានិច្ច័យបង់ចូលរតនាគារជាតិ ។

**ប្រការ ៨ .–**

គណនេយ្យកររងម្នាក់ៗ ត្រូវស្ថិតនៅក្រោមអំណាចផ្ទាល់ តាមឋានានុក្រមរបស់គណនេយ្យករដើមខ្សែ ។

គណនេយ្យករដើមខ្សែ ត្រូវស្ថិតនៅក្រោមអំណាចផ្ទាល់ តាមឋានានុក្រមរបស់ប្រធានសាខាពន្ធដារខេត្ត–ក្រុង ។

**ប្រការ ៩ .–**

ការងារដែលជាបន្ទុករបស់អាណាប័កទទួលសិទ្ធិប្រទាន ព្រមទាំងការងាររបស់គណនេយ្យករដើមខ្សែ និងគណនេយ្យកររង ហើយនិងទំនាក់ទំនងការងាររវាងផ្នែកទាំងនេះ ត្រូវបានកំណត់បញ្ជាក់ដោយកំណត់ណែនាំមួយដោយឡែក ។

**ប្រការ ១០ .–**

នីតិវិធី និង បរិបថ នៃការផ្ទេរប្រាក់ចំណូលសារពើពន្ធបង់ចូលរតនាគារជាតិ ត្រូវបានណែនាំដោយសារាចររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ១១ .–**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

**គាត ឈន់**

* * *